00153003

C23

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**Declassified to Public**
**06 September 2012**

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០១/១៨-២០០៧-អវតក-កសចស (អបជ០១ )

# អង្គបុរេជំនុំជម្រះ

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan Downing
ចៅក្រម ប៉ែន ពេជ្រសាលី
ចៅក្រម Katinka Lahuis
ចៅក្រម ហួត វុទ្ធី

ORIGINAL DOCUMENT RECEIVED ON 21/11/2007 AT 8:45' BY NUP SOTHUNVICHET ACTING CASE FILE OFFICER

កាលបរិច្ឆេទ: ២០ វិច្ឆិកា ២០០៧

---

# សេចក្តីសម្រេចស្តីពីសេចក្តីជូនដំណឹងអំពីប្រតិភូកម្មអំណាចរបស់សហព្រះរាជអាជ្ញា ក្នុងរឿងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន

---

<u>ការិយាល័យសហព្រះរាជអាជ្ញា</u>
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH

<u>ជនត្រូវចោទ</u>
កាំង ហ្កេកអ៊ាវ ហៅ ឌុច

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le) 21 ខែ(Month/Mois) NOV.
ឆ្នាំ(Year/Année) 2007
Greffier NUP SOTHUN VICHET

<u>មេធាវីការពារក្តី</u>
ការ សាវុត
François ROUX

C23

# អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អវតក"

**បានឃើញ** សេចក្តីជូនដំណឹងអំពីប្រតិភូកម្មអំណាចរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៧ អនុលោមតាមវិធាន ១៣-១ និង វិធាន ១៣-៤ នៃវិធានផ្ទៃក្នុង

## សម្រេចដូចខាងក្រោម

១- ក្នុងពេលសវនាការជាសម្ងាត់នៅថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ក្នុងរឿងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន សហព្រះរាជអាជ្ញាបានជូនដំណឹងជាសាធារណៈដល់អង្គបុរេជំនុំជម្រះអំពីបំណងចង់ធ្វើប្រតិភូកម្មអំណាចទៅឲ្យព្រះរាជអាជ្ញារង ជំនួយការជាន់ខ្ពស់ និងជំនួយការព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់នៅគ្រប់សវនាការទាំងអស់។

២- ក្នុងពេលសវនាការនោះ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវីជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋានតប រហូតដល់ថ្ងៃទី ១៩ ខែវិច្ឆិកា ម៉ោង ១២:០០ ប៉ុន្តែអង្គបុរេជំនុំជម្រះមិនបានទទួលការឆ្លើយតបឡើយ។

៣- បន្ទាប់ពីបានពិនិត្យមើលសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញារួចមក អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សហព្រះរាជអាជ្ញាមិនបានស្នើសុំសេចក្តីសម្រេច ឬដីកាជាក់លាក់ណាមួយពីអង្គបុរេជំនុំជម្រះ ជាពិសេសទាក់ទងនឹងសវនាការដែលត្រូវធ្វើឡើងនៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឡើយ។ សហព្រះរាជអាជ្ញាគ្រាន់តែជូនដំណឹងដល់អង្គបុរេជំនុំជម្រះអំពីបំណងផ្ទេរសិទ្ធិទៅឲ្យព្រះរាជអាជ្ញារង ជំនួយការជាន់ខ្ពស់ និងជំនួយការព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋាននៅគ្រប់សវនាការទាំងអស់ប៉ុណ្ណោះ។

៤- តាមវិធាន ២ និង វិធាន៣ កិច្ចប្រជុំពេញអង្គសម្រាប់ចៅក្រមមានយុត្តាធិការពិសេសធ្វើវិធានទូទៅសម្រាប់ **អវតក**។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះមិនមានយុត្តាធិការធ្វើសេចក្តីប្រកាស ឬដីកាទូទៅណាមួយឡើយ។ អង្គបុរេជំនុំជម្រះគ្រាន់តែធ្វើការទៅលើបញ្ហាទាក់ទងនឹង

ករណីពិសេសក្នុងវង្វង់យុត្តាធិការរបស់ខ្លួន ដូចមានចែងក្នុងវិធានផ្ទៃក្នុងប៉ុណ្ណោះ។ ដូច្នេះ អង្គបុរេជំនុំជម្រះមិនអាចចេញសេចក្តីសម្រេច ឬដីកាក្នុងរឿងទូទៅតាមការស្នើសុំរបស់សហព្រះរាជអាជ្ញាបានទេ។

៥- ទាក់ទងនឹងសំណើខាងលើនេះ អង្គបុរេជំនុំជម្រះបានកត់សំគាល់ឃើញថា ថ្ងៃសវនាការត្រូវបានជូនដំណឹងមុនរួចហើយ។ មុន ឬ ចាប់តាំពីកំណត់កាលបរិច្ឆេទទាំងនេះ អង្គបុរេជំនុំជម្រះមិនបានទទួលដំណឹងពីអលទ្ធភាពក្នុងការចូលរួមសវនាការចំពោះមុខអង្គបុរេជំនុំជម្រះរបស់សហព្រះរាជអាជ្ញាណាមួយឡើយ។ សូម្បីតែក្នុងពេលធ្វើការជូនដំណឹង សហព្រះរាជអាជ្ញាក៏មិនបានបញ្ជាក់អំពីអលទ្ធភាពក្នុងការចូលរួមសវនាការចំពោះមុខអង្គបុរេជំនុំជម្រះរបស់ខ្លួនដែរ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការចូលរួមសវនាការក្នុងរឿងបណ្តឹងឧទ្ធរណ៍នេះដោយផ្ទាល់របស់សហព្រះរាជអាជ្ញា ជាការសំខាន់ណាស់ ពីព្រោះវាជាបណ្តឹងឧទ្ធរណ៍លើកដំបូងដែលធ្វើឡើងមកអង្គបុរេជំនុំជម្រះដែលត្រូវបើកសវនាការជាសាធារណៈ។

៦- លើសពីនេះ អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា មាត្រា ២២ (ថ្មី) នៃច្បាប់អវតកត្រូវបានដកស្រង់ និងលើកឡើងដោយសហព្រះរាជអាជ្ញា ត្រង់កថាខ័ណ្ឌទី៣ ក្នុងសេចក្តីជូនដំណឹងរបស់ខ្លួន។ មាត្រា ២២ (ថ្មី) នៃច្បាប់អវតក ចែងថា:

*សហព្រះរាជអាជ្ញាមួយរូបៗមានសិទ្ធិជ្រើសរើសព្រះរាជអាជ្ញារងមួយរូប ឬច្រើនរូប ដើម្បីជួយខ្លួនក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ព្រះរាជអាជ្ញារងបរទេស ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពីបញ្ជីផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។*

*សហព្រះរាជអាជ្ញាត្រូវមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិ ជាជំនួយការទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន។*

*ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ ប្រធានការិយាល័យរដ្ឋបាលត្រូវសម្អាសន៍ក្នុងករណីចាំបាច់ និងត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាខ្មែរ ក្នុងការជួលបុគ្គលិកដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវចំពោះ*

00153006

C23

ការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិបរទេសទាំងអស់។ចំនួនបុគ្គលិកជំនួយការត្រូវជ្រើសរើសតាមសមាត្រព្រះរាជអាជ្ញាខ្មែរ និងព្រះរាជអាជ្ញាបរទេស។

បុគ្គលិកជាជំនួយការត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្របខណ្ឌរដ្ឋ ឬជនជាតិខ្មែរដ៏ទៃទៀត ដែលមានសមត្ថភាពក្នុងករណីចាំបាច់។

៧- ដូច្នេះ កត់សំគាល់ឃើញថា មានតែព្រះរាជអាជ្ញារង ប៉ុណ្ណោះដែលអាចជួយសហព្រះរាជអាជ្ញា ក្នុងការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គបុរេជំនុំជម្រះនៃអវតក។

៨- លើសពីនេះ កត់សំគាល់ឃើញថា អ្នកដែលតែងតាំងជាព្រះរាជអាជ្ញារង ត្រូវតែមានសមត្ថភាព។

៩- អង្គបុរេជំនុំជម្រះកត់សំគាល់ក្នុងសវនាការ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឃើញថា សេចក្ដីសន្និដ្ឋានតប សហព្រះរាជអាជ្ញា ទៅនឹងរឿងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញារង។ ភាគីត្រូវបានអនុញ្ញាតឲ្យដាក់សេចក្ដីសន្និដ្ឋាន រហូតដល់ថ្ងៃសវនាការអង្គបុរេជំនុំជម្រះ។ ដើម្បីជៀសវាងបញ្ហាបច្ចេកទេស អង្គបុរេជំនុំជម្រះស្នើឲ្យសហព្រះរាជអាជ្ញាបញ្ជាក់ថា ខ្លួនទទួលយក ហើយខ្លួនចង់ធ្វើសេចក្ដីសន្និដ្ឋានដូចមានចែងក្នុងសេចក្ដីសន្និដ្ឋានតប។

១០- តុលាការអន្តរជាតិផ្សេងទៀតមានលក្ខខណ្ឌរបស់ខ្លួនដែលត្រូវបំពេញ ក្នុងការផ្ទេរអំណាច ហើយពួកគេមានលក្ខណៈប្រាកដប្រជាណាស់។ ការអនុវត្តក្នុងការផ្ទេរអំណាចនៅកន្លែងផ្សេង មិនបានផ្ដល់អំណាចបែបនេះក្នុង អវតក ឡើយ ខណៈពេលលក្ខខណ្ឌវិធានផ្ទៃក្នុងរបស់ អវតក មិនពានបំពេញនោះ។

ភ្នំពេញ, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧

ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ប្រាក់ គឹមសាន

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh